# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១ អនក្រ

# សេចក្ដីសម្រេច

## ស្ដីពី

## ការកែតម្រូវសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ

-----------

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ១៥សសរ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ

## សំរេច

**ប្រការ ១.-**

ប្រការ១ នៃសេចក្តីសំរេចលេខ ១៥សសរ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ត្រូវបានកែតម្រូវដូចខាងក្រោម :

**ប្រការ ១ថ្មី.-**

ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដែលមានសមាសភាពដូចតទៅ :

- ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
- ឯកឧត្តម **ព្រំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តមនាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ុល សារឿន** អគ្គមេបញ្ជាការរង នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អនុប្រធាន
- ឯកឧត្តម **កែវ សាផល** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធានប្រចាំការ
- ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- ឯកឧត្តម **ផាន់ ខូន** អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ សមាជិក
- ឯកឧត្តម **ហែម ក្រាញ់ តូនី** អនុរដ្ឋលេខាធិការទីស្តីការណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **មាស គីមសុទ្ធារី** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- ឯកឧត្តម **សួ ម៉ារ៉ា** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
- ឯកឧត្តម **ម៉ៅ ថូរ៉ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

- ឯកឧត្តម **ម៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **ពៅ សាមី** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
- ឯកឧត្តម **ខាំ សុខុម** អគ្គលេខាធិការរងទី១នៃអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
- ឯកឧត្តមឧត្តមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- ឯកឧត្តមឧត្តមសេនីយ៍ **សឹង សំណាង** មេបញ្ជាការកងទ័ពជើងអាកាស សមាជិក
- ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ សមាជិក
- លោក **អ៊ុង អឿន** អភិបាលរងទី១ខេត្តសៀមរាប សមាជិក
- លោក **ម៉ុន នី** ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងជាប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សមាជិក
- លោក **ម៉ុន រដ្ឋា** ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិសៀមរាប និងជាប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិសៀមរាប សមាជិក

**ប្រការ ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ថ្មី ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ